# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ភាគីដាក់ឯកសារ:** សហមេធាវីរបស់លោក នួន ជា

**ដាក់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2016, 11:32
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ (កោសលុប)

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

**សំណើលើកទីបួនរបស់ នួន ជា សុំសាក្សីសម្រាប់វគ្គមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ក្នុងសំណុំរឿង ០០២/០២ (ដំណើរការមន្ទីរសន្តិសុខ ស-២១ និងភស្តុតាងជាឯកសារ)**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា÷**

សុន អរុណ

Victor KOPPE

លីវ សុវណ្ណា

Doreen CHEN

ព្រុំ ផល្លា

Xiaoyang NIE

Marina HAKKOU

Léa KULINOWSKI

ឌី សុជាតា

**ផ្ញើជូន÷**

**សហមេធាវីរបស់ ខៀវ សំផន÷**

គង់ សំអុន

Anta GUISSÉ

**សហព្រះរាជអាជ្ញា÷**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី÷**

ពេជ អង្គ

Marie GUIRAUD

# I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៩១(១) និង ៨៧(៤) នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") សូមដាក់សំណើនេះ ("សំណើ") ទាក់ទិននឹងសាក្សីចំនួនដប់ រូបដែលអាចផ្តល់ភស្តុតាងពាក់ព័ន្ធនឹងបញ្ហារងការជំទាស់សំខាន់ៗនៅក្នុងវគ្គសវនាការស្តីពីមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ក្នុងសំណុំរឿង ០០២/០២ ។

2. មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះឲ្យពន្លឿនសក្ខីកម្មរបស់បុគ្គលប្រាំពីររូបដែលបានស្នើកាលពីមុនដោយមេធាវីការពារក្តី និងដែលអាចផ្តល់ភស្តុតាងសំខាន់និងមិនអាចរកបានទាក់ទងនឹងមន្ទីរ ២១ និងការបោសសម្អាតផ្ទៃក្នុង។ សាក្សីពីររូបកក្នុងចំណោមនោះរួមមាន [redacted] (2-TCW-864)[1] [redacted] (2-TCW-854)[2] ដែលបានធ្វើការនៅទីនោះ។ សាក្សីទីបីគឺ [redacted] (2-TCW-956)[3] ដែលជាប់ឃុំនៅមន្ទីរស២១ និង [redacted] (2-TCW-870)[4] និង [redacted] (2-TCW-814)[5] ដែលបានធ្វើការនៅសារមន្ទីរទួលស្លែងបន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណែក [redacted] (2-TCW-946)[6] គឺជាអ្នកនិពន្ធភាពយន្តឯកសារ [redacted] ដែលត្រូវបានទទួលយកជាភស្តុតាង ។ បុគ្គលទាំងបីនេះអាចអាចផ្តល់ភស្តុតាងសំខាន់ទាក់ទិននឹងឯកសារដើមដែលបានរកឃើញនៅមន្ទីរសន្តិសុខ ស-២១ ពីរបីខែក្រោយពីការដួលរលំនៃរបបខ្មែរក្រហម។

3. បន្ថែមពីលើនេះ មេធាវីការពារក្តីស្នើអង្គជំនុំជម្រះកោះហៅសាក្សីបីរូបបន្ថែមទៀត ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង មានជាអាទិ៍ [redacted] (សាក្សីទី១) [redacted] (សាក្សីទី២) ដែលជាអ្នករៀបចំបញ្ជីឈ្មោះអ្នកទោសស២១ ព្រមទាំង [redacted]

---

[1] ឯកសារ E305/4.2 "ឧបសម្ព័ន្ធ ខ៖ សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ (មិនសុំវិធានការការពារ)" ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤ ("សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី") ទំព័រ ២៤ លេខ ១៨។

[2] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ២៨ លេខ ២១។

[3] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ២៣ លេខ ១៧។

[4] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ៦ លេខ ៥។

[5] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ៥ លេខ ៤។

[6] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ១៤ លេខ ១០។

(សាក្សីទី៣) ដែលបានផ្តល់រូបថតស២១ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ សាក្សីទាំងនេះអាចផ្តល់ភ័ស្តុតាងសំខាន់សម្រាប់វគ្គសវនាការស្តីពីមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ក្នុងសំណុំរឿង ០០២/០២ នាពេលនេះ ទាក់ទិននឹងភ័ស្តុតាងជាឯកសារសំខាន់ៗក្នុងសំណុំរឿង ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១។

4. គោលជំហររបស់មេធាវីការពារក្តីគឺថា បុគ្គលភាគច្រើនដែលត្រូវបានចោទប្រកាន់ថា បានចុះឈ្មោះនៅស២១ គឺមិនបានជាប់ឃុំ និង/ឬ សម្លាប់នៅស២១ទេ។ តែផ្ទុយទៅវិញបុគ្គលភាគច្រើនដែលមាននៅក្នុងបញ្ជី ដែលហៅថា បញ្ជីអ្នកទោសស-២១នោះ គឺគ្រាន់តែកត់នៅស២១ប៉ុណ្ណោះ និងបន្ទាប់មកត្រូវបានបញ្ជូនទៅព្រៃស[7] (ដែលជាផ្នែកមួយនៃ ស២១ នេះបើតាម កសចស)[8] ទៅព្រលានយន្តហោះកំពង់ឆ្នាំង[9] ទៅមន្ទីរអប់រំកែប្រែផ្សេងទៀត[10] ឬក៏ត្រូវបានដោះលែង[11]។ មេធាវីការពារក្តីកត់សម្គាល់ថា ភស្តុតាងនៅក្នុងសំណុំរឿងហាក់ដូចជាបង្ហាញថា មានបុគ្គលប្រហែល៥០០០នាក់ ត្រូវបានសម្លាប់នៅស២១។ មានហ្វីលរូបថតដែលត្រូវបានថតនៅស២១ប្រហែល ៦០០០ ត្រូវបានរកឃើញនៅឆ្នាំ១៩៩៤[12]។ បើតាម David Chandler ដែលជាអ្នកជំនាញត្រូវបានទទួលស្គាល់ថា នាំមុខគេទៅលើស២១ ដែលបាននិយាយថា មានប្រវត្តិរូបប្រហែល

---

[7] E3/7639, កំណត់ហេតុស្តាប់ចម្លើយ [redacted]។

[8] D427 ដីកាដំណោះស្រាយ កថាខណ្ឌ ៤១៥។

[9] *សូមមើល* E3/7532 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ [redacted] ERN 00329478។

[10] *សូមមើល* E3/7664 កំណត់ហេតុស្តាប់ចម្លើយ [redacted] ERN 00163804។ E3/7543,កំណត់ហេតុស្តាប់ចម្លើយ គុប រី ERN 00324274-75។

[11] *សូមមើល* E393.2 កសចស បញ្ជីឈ្មោះអ្នកទោស ថ្ងៃទី ៣១ មីនា ឆ្នាំ២០១៦ លេខរៀង7390, 7396, 7397, 7399, 7405, 7406, 7409 , 7412, 7421, 7443, 7445, 7450, 7453, 7460, 7469, 7475, 7479 ។

[12] E3/1684, សៀវភៅសរសេរដោយ DAVID Chandler: "សម្លេងពីមន្ទីរស២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ប៉ុលពត", ERN: 00192676; E3/3088R, ការងារសម្ងាត់របស់ ស២១ នៅ 02.17-02.32; E3/8639 មានរូបថតស២១ចំនួន 5,186។ មេធាវីការពារក្តីដឹងថា សហព្រះរាជអាជ្ញាបានទទួលរូបថតចំនួន 1,405 តែមេធាវីការពារក្តីកត់សម្គាល់ឃើញថា ពុំមានព័ត៌មានអំពីប្រភព ឬយថាភាពនោះទេ ហើយរូបថតទាំងអស់នោះអាចជាន់គ្នានឹងរូបថតដែលត្រូវបានរកឃើញនោះ។ *សូមមើលផងដែរ* E394 សំណើរបស់សហព្រះរាជអាជ្ញាសូមបញ្ចូលរូបថត ស២១។ បញ្ជីដែលបានទទួលស្គាល់ E3/9214, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០១៦។

៤ ៣០០ ត្រូវបានរកឃើញ[13]។ Geng Biao ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិប្រទេសចិននៅក្នុងខែមករា ឆ្នាំ ១៩៧៩ បាននិយាយនៅក្នុងរបាយការណ៍ឆ្នាំ ១៩៨១ ថា មាន "មនុស្សតែជាង ៤ ០០ ប៉ុណ្ណោះ" ដែលត្រូវបានចាប់ខ្លួន[14]។ សំខាន់ជាងនេះទៀតនោះ បញ្ជីអ្នកទោសស២១ ដែលបានរៀបចំដោយ កសចស មានកាលបរិច្ឆេទសម្លាប់សម្រាប់តែបុគ្គលចំនួន ៥ ៥១២ ក្នុងចំណោម ១៥ ១០១ នាក់ដែលមាននៅក្នុងបញ្ជី[15]។

5. ជាលទ្ធផល ភស្តុតាងដែលបានផ្តល់ដោយសាក្សី ដែលជាកម្មវត្ថុនៃសំណើនេះគឺជាផ្នែកស្នូលរបស់មេធាវីការពារក្តី។ សំណើនេះគឺជាសំណើលើកទីបួន ក្នុងចំណោមសំណើសុំកោះហៅសាក្សីជាបន្តបន្ទាប់ដែលមេធាវីការពារក្តីបានស្នើសុំទាក់ទិននឹងវគ្គនេះ[16]។

## II. សាវតារ និង ប្រវត្តិនីតិវិធី

6. ដូចដែលមេធាវីការពារក្តីបានបញ្ជាក់ជូនអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណើសុំសាក្សីទាក់ទងនឹងភូមិភាគបូព៌ានៅខែ កញ្ញា ឆ្នាំ ២០១៥[17] ផ្នែកស្នូលនៃសំណុំរឿងមេធាវីការពារក្តីនោះគឺថា ក្រៅពីមានឋានានុក្រម "រាងពីរ៉ាមីត" មានវិន័យ មានការឯកភាពគ្នា ប.ក.ក ហ៊ុំព័ទ្ធទៅដោយការរង្គោះរង្គើផ្ទៃក្នុងជាប្រចាំ ហើយក្រុមមានកម្លាំងខ្លាំងស្មើគ្នា និងផ្សេងៗគ្នា (រួមទាំងក្រុមមួយដែលបានដឹកនាំដោយលេខាភូមិភាគបូព៌ា សោ ភឹម និងលេខាភូមិភាគពាយ័ព្យ រស់ ញឹម) បានអនុវត្តកម្មវិធីប្រណាំងប្រជែងគ្នាក្នុងគោលបំណងចាប់យកការគ្រប់គ្រងបក្ស និងប្រទេសទាំងមូល ព្រមទាំងក្រុមមួយក្នុងចំណោមក្រុមទាំងនេះក៏ព្យាយាមតស៊ូដើម្បីផលប្រយោជន៍យ៉ាងហោចណាស់សម្រាប់វៀតណាម បើមិនសម្រាប់សហភាពសូវៀតទេនោះ។ បញ្ហាលម្អិតត្រូវបានរៀបរាប់នៅក្នុងសំណុំរឿងរបស់មេធាវីការពារក្តី ដែលបានដាក់ជូនជាសាធារណៈដល់អង្គជំនុំ

---

[13] E3/1684, សៀវភៅសរសេរដោយ DAVID Chandler: "សម្លេងពីមន្ទីរស២១៖ ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ប៉ុលពត" 00192674, 00192685។

[14] E3/7325 របាយការណ៍របស់ Geng Biao អំពីស្ថានភាពនៅឧបទ្វីបឥណ្ឌូចិន ERN 01001623។

[15] E393.2 កសចស បញ្ជីឈ្មោះអ្នកទោស ថ្ងៃទី ៣១ មីនា ឆ្នាំ២០១៦ ក្រឡោណទី១៤ ថ្ងៃចូលទទេ។

[16] *សូមមើល ខាងក្រោម* នៅត្រង់កថាខណ្ឌ ៨។

[17] **E370** "សំណើបន្ទាន់ និង រួមគ្នារបស់ នួន ជា សុំឱ្យពន្លឿនសំណើពីររបស់ខ្លួនដែលបានស្នើរួចហើយ និងសុំឱ្យកោះហៅសាក្សីបន្ថែមបួនរូប ពាក់ព័ន្ធការប្រព្រឹត្តចំពោះជនជាតិចាម" ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ("សំណើសុំសាក្សីភូមិភាគបូព៌ា") កថាខណ្ឌ ២៥។

ជម្រះតុលាការកំពូល[18]។

## ក. បញ្ជីឈ្មោះសាក្សីក្នុងសំណុំរឿង ០០២/០២

7. នៅថ្ងៃទី ៨ និងទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តី និងភាគីផ្សេងទៀតបានដាក់បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលភាគីស្នើសុំ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពសម្រាប់សំណុំរឿង ០០២/០២[19]។ បញ្ជីសាក្សីដែលត្រូវបានធ្វើបច្ចុប្បន្នភាពរបស់មេធាវីការពារក្តី ("បញ្ជីសាក្សីដែលត្រូវបានធ្វើបច្ចុប្បន្នភាព") រួមមាន [redacted] (2-TCW-814)[20] [redacted] (2-TCW-870)[21] [redacted] (2-TCW-946)[22] [redacted] (2-TCW-864)[23] និង [redacted] (2-TCW-854)[24]។

8. នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញថ្មីសម្រាប់សំណុំរឿង ០០២/០២[25] ("បញ្ជីឈ្មោះសាក្សីថ្មី")។ បញ្ជីឈ្មោះសាក្សីថ្មីរបស់មេធាវីការ

---

[18] *សូមមើល*ជាពិសេស **F2/8** "សំណើទី៦ របស់ នួន ជា ស្នើសុំឲ្យមានការពិចារណា និងទទួលយកភ័ស្តុតាងបន្ថែមទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៥ កថាខណ្ឌ ២៣ ដល់៦៩។

[19] ឯកសារ E305/4 "បញ្ជីឈ្មោះ និងព័ត៌មានសង្ខេបដែលបានធ្វើបច្ចុប្បន្នភាព ស្តីពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើសុំ" ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ E305/5 "សាក្សី និងអ្នកជំនាញស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២" ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ E305/6 "បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា និងសេចក្តីសង្ខេបសម្រាប់ជំនុំជម្រះក្នុងសំណុំរឿងលេខ ០០២/០២ (ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន ៥៖ I, II, IIក, III និង IIIក)" ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ E305/7 "បញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨០ របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង ០០២/០២ ដោយមានឧបសម្ព័ន្ធសម្ងាត់" ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤។

[20] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ៥ លេខ ៤។

[21] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ៦ លេខ ៥។

[22] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ១៤ លេខ ១០។

[23] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ២៤ លេខ ១៨។

[24] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ២៨ លេខ ២១។

[25] ឯកសារ E307/4 "បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មី សម្រាប់សំណុំរឿង ០០២/០២" ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤។

ពារក្តីមានបញ្ចូលឈ្មោះ [redacted] (2-TCW-963)[26]។

## ខ. សាក្សីសម្រាប់ប្រធានបទអំពីមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង"

9. នៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះមនុស្សចំនួនប្រាំបួននាក់ដំបូងដែលត្រូវមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ក្នុងនាមជាសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិននឹងមន្ទីរសន្តិសុខ ស-២១[27]។ មនុស្សដំបូងដែលបានមកផ្តល់សក្ខីកម្មនៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ហើយកន្លងមកមានមនុស្សចំនួនប្រាំពីរនាក់បានផ្តល់សក្ខីកម្មរួចហើយ (សាក្សីប្រាំមួយនាក់ និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់)។ នៅក្នុងសារអេឡិចត្រូនិកដដែលនោះ អង្គជំនុំជម្រះបានបញ្ជាក់ថា "បញ្ជីឈ្មោះសាក្សីសម្រាប់ប្រធានបទរងដែលនៅសល់ស្តីពី "ការបោសសម្អាតផ្ទៃក្នុង" នឹងត្រូវជូនដំណឹងដល់ភាគី តាមពេលវេលាសមស្រប"។

10. នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើសាក្សីលើកទីមួយរបស់ខ្លួនសុំកោះហៅសាក្សីសម្រាប់វគ្គមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ដោយស្នើសុំកោះហៅសាក្សីប្រាំមួយនាក់មកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងកងពលយោធា ៣១០ ដែលមានទំនាក់ទំនងនឹងភូមិភាគឧត្តរ[28]។ នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើលើកទីពីររបស់ខ្លួន សុំកោះហៅសាក្សីសម្រាប់វគ្គមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ដោយស្នើសុំកោះហៅសាក្សីប្រាំបីនាក់មកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការដឹកនាំនៃការបះបោរ[29]។ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើលើកទីបីរបស់ខ្លួន សុំកោះហៅសាក្សីសម្រាប់វគ្គមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ដោយស្នើសុំអង្គជំនុំជម្រះពន្លឿនការកោះហៅសាក្សីបួនរូបមកបង្ហាញខ្លួន និងស្នើសុំកោះហៅសាក្សីចំនួនប្រាំពីរនាក់មកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបះបោរក្បត់នៅភូមិភាគពាយ័ព្យ ភូមិភាគបូព៌ា និងភូមិភាគឦសាន[30]។

---

[26] ឯកសារ E307/4 "បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មី សម្រាប់សំណុំរឿង ០០២/០២" ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥។

[27] ឯកសារ E391.1.1 សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគី ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៦។

[28] ឯកសារ E391 សំណើលើកទីមួយស្នើសុំសាក្សី (កងពលធំលេខ ៣១០)។

[29] ឯកសារ E392 "សំណើលើកទីពីរស្នើសុំសាក្សី (មេដឹកនាំ)" ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៦។

[30] ឯកសារ E395 "សំណើលើកទីបីស្នើសុំសាក្សី (ភ័ស្តុតាងអំពីការបះបោរក្បត់)" ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៦។

11. អង្គជំនុំជម្រះមិនទាន់បានសម្រេចលើសំណើសុំសាក្សីទាំងបីនេះទេ។ ជាងនេះទៀត នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានចេញអនុស្សរណៈមួយដោយតម្រូវឱ្យមេធាវីការពារក្ដី ផ្ដល់នូវព័ត៌មានបន្ថែមទៀតស្ដីពីភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់សាក្សីដែលបានស្នើសុំកន្លងមក ទាក់ទិននឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និង ជាពិសេស៖

> តើអត្ថិភាពនៃក្រុមជម្លោះទាំងនោះអាចផ្ដល់ការការពារខ្លួនចំពោះបទចោទនានានៅក្នុងដីកាដំណោះស្រាយដោយរបៀបណា ឬ ថាតើអត្ថិភាពនេះអាចចាត់ទុកថាជាស្ថានភាពសម្រាលដោយរបៀបណា[31]។

## គ. បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស

12. នៅថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១៦ ភាគីបានទទួលព័ត៌មានថា ក.ស.ច.ស បានបង្កើតបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ ដែលបានប្រើអស់រយៈពេល ២ ឆ្នាំ ("បញ្ជីរបស់ ក.ស.ច.ស")។ បញ្ជីនេះមានឈ្មោះ ១៥ ១០១ ឬ លើសពីបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ ដែលរៀបចំដោយ ក.ស.ព ចំនួន ២.៨២៨ នាក់[32]។ បើតាម ក.ស.ច.ស ការិយាល័យនេះបានពិនិត្យឯកសារចំនួន ១៣ ៣៨៣ រួមទាំងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ បញ្ជីឈ្មោះអ្នកចូល ជីវប្រវត្តិអ្នកទោស កម្មាភិបាលនៅមន្ទីរសន្តិសុខ ស-២១ បញ្ជីសួរចម្លើយ និងបញ្ជីសម្លាប់[33]។ នៅក្នុងចំណោមឯកសារ ១៣ ៣៨៣ ឯកសារចំនួន ៨៧១ ត្រូវបានប្រើប្រាស់ដោយ ក.ស.ច.ស នៅក្នុងការរៀបចំបញ្ជី[34]។ បន្ទាប់ពីភាគីបានលើកសេចក្ដីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួនទាក់ទិននឹងភាពអាចទទួលយកបាននូវឯកសារទាំងនេះ[35] នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានផ្ញើអនុស្សរណៈមួយច្បាប់ ដោយទទួលយកឯកសារទាំងអស់ដែលជាមូលដ្ឋាននៃបញ្ជីរបស់ ក.ស.ច.ស និងតារាងជាកម្មវិធី excel ដែលមានភ្ជាប់មកជាមួយ៖១) រៀបរាប់ជាឯកសារពាក់ព័ន្ធ E3 ដែលត្រូវបានយោងនៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានទទួលយករួចហើយនៅ

---

[31] ឯកសារ E395/1 "សំណើសុំសារណាសង្ខេបស្ដីអំពីសារៈសំខាន់នៃក្រុមជម្លោះនៅក្នុងថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ" ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦ លេខ ERN 01240210។

[32] ឯកសារ E393.2 "បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ របស់ ក.ស.ច.ស" ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦។

[33] ឯកសារ E393.1 "អនុស្សរណៈអន្តរការិយាល័យដោយពិចារណា "បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស និងពន្យល់អំពីវិធីសាស្ត្រដែលបានអនុវត្ត"" ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦។

[34] E393/1.1 តារាងឯកសារដែលជាបញ្ជីអ្នកទោស ស២១, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦។

[35] សេចក្ដីព្រាងប្រតិចារឹកសវនាការ ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៦ ពីម៉ោង [១៣:៤៤:៥៨]។

ក្នុងសំណុំរឿង ០០២/០២ និង ២) ចាត់ថ្នាក់ជាឯកសារ E3 ថ្មី ចំពោះឯកសារទាំងនោះដែលត្រូវបានទទួលយកនាពេលនេះ[36]។

13. នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ មេធាវីរបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមានការពន្យារពេល ដោយពុំមានសវនាការនៅតុលាការ ចំនួន ៤ សប្តាហ៍ដើម្បីការពារសិទ្ធិជាសារវ័ន្តរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងពិសេស សិទ្ធិរបស់គាត់ក្នុងការត្រៀមរៀបចំសម្រាប់ការពិនិត្យសាក្សី និងបង្ហាញភស្តុតាង។ សំណើនេះផ្អែកលើការកែប្រែកាលវិភាគសវនាការ និងសាក្សី ឯកសារដែលត្រូវបានដាក់បង្ហាញថ្មីៗ ព្រមទាំងចំនួនសម្ភារៈដែលត្រូវពិនិត្យមើលក្នុងការត្រៀម រៀបចំសម្រាប់សាក្សី ស២១ ដែលនៅសេសសល់ (ហ៊ឹម ហ៊ុយ, 2-TCW-816 និង ឌុច)[37]។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចខ្លួនដោយផ្ទាល់មាត់នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៦[38] និងបានផ្តល់សំអាងហេតុជាលាយលក្ខណ៍អក្សរនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦[39] ដោយបានឯកភាពមួយផ្នែកចំពោះសំណើនេះ។

14. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានស្នើដល់អង្គជំនុំជម្រះឲ្យពិចារណាសេចក្តីសម្រេចរបស់ខ្លួន និងបង្គាប់ថា សាក្សី 2-TCW-906 និង ឌុច គួរតែត្រូវសួរដោយ សហព្រះរាជអាជ្ញានៅក្នុងកាលវិភាគក្នុងពេលបច្ចុប្បន្ន និងបន្តសួរដោយមេធាវីការពារក្តីនៅបីសប្តាហ៍បន្ទាប់ពីសហព្រះរាជអាជ្ញាដោយពុំមានការស្តាប់ចម្លើយសាក្សីណាមួយនៅក្នុងអំឡុងពេលនោះទេ[40]។ សំណើពឹងផ្អែកដោយផ្អែកទៅលើអង្គហេតុថា ការវិភាគជាបឋមរបស់មេធាវីការពារក្តីបានលើកឡើងការព្រួយបារម្ភមួយចំនួនទាក់ទងនឹងយថាភាព និង ភាពអាចជឿជាក់បានរបស់ឯកសារបញ្ជី

---

[36] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនភាគី ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦។

[37] ឯកសារ E402, "សំណើបន្ទាន់របស់ នួន ជា សុំពេលវេលាបន្ថែមដើម្បីរៀបចំសម្រាប់ការពិនិត្យសាក្សី ស២១ ដែលនៅសល់ដើម្បីការពារដល់សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌", ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ("សំណើដំបូង")។

[38] ប្រតិចារឹក, ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៦ (ទឡ្ហីករណ៍ផ្ទាល់មាត់ស្តីពីឯកសារ E402, ថ្ងៃទី ៤០៧) នៅម៉ោង ១៣.៣១.០៨។

[39] ឯកសារ E402/1, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំផ្អាកសវនាការ (E402), ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦។

[40] សារអេឡិចត្រូនិចពីមេធាវីការពារក្តីជូនអង្គជំនុំជម្រះសាលាដំបូង។

ក.ស.ច.ស[41]។ នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានផ្តល់ដោយផ្ទែកទៅលើ សំណើ និង បានលើកពេលសវនាការរហូតដល់ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៦[42]។

## III. ច្បាប់ជាធរមាន

### ក. ការពន្លឿនការកោះហៅសាក្សី

15. អនុលោមតាមវិធាន ៩១(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការ "ស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញតាមលំដាប់លំដោយ នៅពេលអង្គជំនុំជម្រះពិចារណាថាមានប្រយោជន៍"។ អង្គជំនុំជម្រះធ្លាប់បានប្រើសិទ្ធិអំណាចរបស់ខ្លួន កាលពីពេលកន្លងមក អនុលោមតាមវិធាន ៩១(១) នៃវិធានផ្ទៃក្នុង ដើម្បីពន្លឿនការកោះហៅ ថេត សម្បត្តិ មកផ្តល់សក្ខីកម្ម នៅពេលដែលអង្គជំនុំជម្រះពិចារណាថា "មានប្រយោជន៍" ក្នុងការធ្វើបែបនេះ[43]។ សំណួរថា តើភស្តុតាងអាចជួយដល់ការស្វែងរកការពិត គឺសំខាន់ក្នុងការកំណត់ថាគួរពន្លឿនសាក្សីឬក៏អត់[44]។

16. អនុលោមតាមវិធាន ៣៥ ថ្មី នៃច្បាប់ស្តីអំពីការបង្កើត អវតក ជនជាប់ចោទមានសិទ្ធិជាមូលដ្ឋានក្នុងការបង្ហាញ និង ពិនិត្យភស្តុតាង នៅក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងភស្តុតាងប្រឆាំងគាត់។ ហើយវាជាកាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការធានានូវសិទ្ធិទាំងនេះ ដើម្បីឲ្យសវនាការប្រព្រឹត្តទៅដោយយុត្តិធម៌ និងឆាប់រហ័ស និងធ្វើទៅដោយគោរពសិទ្ធិពេញលេញរបស់ជនជាប់ចោទ និងសម្រាប់ការពារដល់ជនរងគ្រោះ និងសាក្សី[45]។ ជាពិសេស ប្រធានរបស់អង្គជំនុំជម្រះត្រូវតែធានាឲ្យមានការអនុវត្តដោយសេរីនូវសិទ្ធិក្នុងការការពារក្តី[46]។

### ខ. ការកោះហៅសាក្សីថ្មីៗ

---

[41] ប្រតិចារិត ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ (អំណះអំណាងផ្ទាល់មាត់របស់មេធាវីការពារក្តី នួន ជា) ទំព័រ ៥ ដល់ ៧។

[42] ប្រតិចារិត ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ (សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ) ទំព័រ ៤៨ នៅ ១៣.៣១.០៨។

[43] ឯកសារ E335/3 "សេចក្តីសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅ ថេត សម្បត្តិ ជាសាក្សីអាទិភាព" ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៥ ("សេចក្តីសម្រេចពន្លឿសការកោះហៅ សម្បត្តិ") កថាខណ្ឌ ៧-៩។

[44] ឯកសារ E335/3 "សេចក្តីសម្រេចពន្លឿសការកោះហៅ សម្បត្តិ" កថាខណ្ឌ ៩។

[45] មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក។

[46] វិធាន ៨៥ នៃ វិធានផ្ទៃក្នុង។

17. វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ផ្តល់សិទ្ធិដល់អង្គជំនុំជម្រះក្នុងការកោះហៅបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សីដែលភស្តុតាងរបស់គាត់ "មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត" តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភាគី។ វិធាននេះតម្រូវឲ្យអង្គជំនុំជម្រះពិចារណាទៅលើអង្គសេចក្តីនៃសំណើ អនុលោមទៅតាមលក្ខខណ្ឌៈវិនិច្ឆ័យនានាដែលមានចែងក្នុងវិធាន ៨៧(៣)នៃវិធានផ្ទៃក្នុង។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្មនោះពុំអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះ[47]។ អង្គជំនុំជម្រះបានសម្រេចថា នៅពេលភាពជាប់ពាក់ព័ន្ធនៃសក្ខីកម្មរបស់បុគ្គលម្នាក់ត្រូវបានបង្ហាញ តែដោយ "ព័ត៌មានតិចតួច" មុនពេលចាប់ផ្តើមជំនុំជម្រះ ទោះបីព័ត៌មានពិស្តារបន្ថែមទៀតអាចរកបានតែក្រោយពេលចាប់ផ្តើមជំនុំជម្រះក៏ដោយ ក៏សក្ខីកម្មដែលលើកឡើងនោះនឹងត្រូវបានចាត់ទុកថាពុំអាចរកបានមុនពេលចាប់ផ្តើមជំនុំជម្រះ[48]។ នៅពេលដែលសក្ខីកម្មអាចរកបានមុនពេលចាប់ផ្តើមជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ទោះជាយ៉ាងណាក្តី ភ័ស្តុតាងនេះអាចត្រូវបានទទួលយក "នៅពេលមានតម្រូវការឲ្យមានប្រយោជន៍យុត្តិធម៌ ជាពិសេស ដរាបណាភ័ស្តុតាងទាំងនេះជាភ័ស្តុតាងដោះបន្ទុក ដែលតម្រូវឲ្យធ្វើការវាយតម្លៃដើម្បីជៀសវាងការសម្រេចសេចក្តីដោយអយុត្តិធម៌"[49] ឬ នៅពេលដែលភ័ស្តុតាងនេះ "ទាក់ទងជិតស្និទ្ធទៅនឹងឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ និង ... ដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យវាយតម្លៃប្រភពទាំងនេះរួមគ្នា"[50]។ ដើម្បីឲ្យស្របទៅនឹងលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ភ័ស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំ

---

[47] អង្គជំនុំជម្រះបានបញ្ជាក់ថា ការចាប់ផ្តើមការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ គឺសវនាការបឋម ដែលបានចាប់ផ្តើមនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១។

[48] ប្រតិចារឹកសវនាការ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ (សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ឯកសារ E1/363.1) ទំព័រ ៤១ បន្ទាត់ ៦-១០។

[49] ឯកសារ E307/1 "សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភ័ស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3)" ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៣ *ស្របទឹង* ឯកសារ E190 "សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត" ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ ("សេចក្តីសម្រេចលើឯកសារថ្មីៗ") កថាខណ្ឌ ៣៦។

[50] ឯកសារ E289/2 "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភ័ស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E289/1)" ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣ *ស្របទឹង* ឯកសារ E190 សេចក្តីសម្រេចលើឯកសារថ្មីៗ កថាខណ្ឌ ៣២។

ជម្រះសាលាដំបូង ត្រូវតែមានភាពពាក់ព័ន្ធ និងអាចជឿជាក់បាន តាមការវិភាគបឋម[51]។

## IV. ឧឡារិករណ៍

18. មេធាវីការពារក្តីសូមលើកឡើងថា រាល់សាក្សីដែលបានស្នើទាំងអស់គឺទាក់ទងដោយផ្ទាល់នឹង ស២១ និងការបោះសម្អាតផ្ទៃក្នុង ហើយអាចផ្តល់ភស្តុតាងដែលមិនអាចរកបាន តែមានទាក់ទងយ៉ាងខ្លាំងទៅនឹងភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។ ឌុច បានប្រាប់អំពីសារសំខាន់នៃមន្ទីរស-២១ ទៅកាន់ ក.ស.ច.ស ដូចតទៅ៖ "ថ្នាក់លើបានបង្ហាញថា ពួកវៀតណាម បានបញ្ជូនភ្នាក់ងារពួកគេមកប្រទេសកម្ពុជា ហើយនេះជាមូលហេតុដែល ស២១ ត្រូវបានចាត់ឲ្យស្វែងរកពួកភ្នាក់ងារទាំងនោះ តាមរយៈចម្លើយសារភាព"[52]។ ដោយសារតែគាត់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ថា ស២១គឺជា "អង្គភាពមួយដើម្បីបំពេញការងារប្រឆាំងនឹងចារកិច្ច"[53]។ ភស្តុតាងរបស់សាក្សីទាំង៩រូបនេះអាចផ្តល់ព័ត៌មានបន្ថែម និងមិនអាចខ្វះបានទៅលើលក្ខណៈពិតប្រាកដនៅ ស២១ ឬក៏សច្ចសីលភាពរបស់ឯកសារ។ ភស្តុតាងនេះគឺបង្ហាញដោយផ្ទាល់ទៅនឹងស្នូលនៃការពារក្តីរបស់មេធាវីការពារក្តី[54]។ ភស្តុតាងអំពីការក្បត់បះបោរប្រឆាំងនឹង បកក និង រដ្ឋាភិបាលស្របច្បាប់ដែលមានការទទួលស្គាល់[55] បូករួមទាំងភស្តុតាងនៅក្នុងសំណើនេះ នឹងបង្ហាញអង្គហេតុខុសគ្នាជាច្រើនសម្រាប់វគ្គសវនាការនេះ។ ភស្តុតាងទាំងនេះមិនគ្រាន់តែផ្លាស់ប្តូរសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" នោះទេ តែវាថែមទាំងលើកលែងការចោទទាំងស្រុង ឬដោយផ្នែកអំពីការទទួលខុសត្រូវរបស់ នួន ជា ចំពោះបទចោទនៅក្នុងដីការដំណោះស្រាយនៅក្នុង

---

[51] ឯកសារ E313 "សាលក្រមក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៦។

[52] ឯកសារ E3/451 កំណត់ហេតុស្តាប់ចម្លើយ ឌុច ខ្មែរ ERN 00187652។

[53] ប្រតិចារិកសវនាការ ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ (កាំង ហ្គេចអ៊ាវ ហៅ ឌុច E1/62.1) ទំព័រ ១០៧ បន្ទាន់ ២-៣។

[54] *សូមមើលកថាខណ្ឌ ៨ ខាងលើ* ។

[55] *សូមមើល*, E391, 'សំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំកោះហៅសាក្សីបន្ថែម និង សំណើអនុលោមតាមវិធាន៩៣ សុំបំពេញកិច្ចស៊ើបសួរបន្ថែម ទាក់ទងនឹងវគ្គសវនាការនៅក្នុងសំណុំរឿង ០០២/០២' ថ្ងៃទី ២៤ មីនា ឆ្នាំ ២០១៦; E392, 'សំណើសុំសាក្សីលើកទីពីររបស់ នួន ជា', ថ្ងៃទី ០១ មេសា ឆ្នាំ ២០១៦; E395, , 'សំណើសុំសាក្សីលើកទីពីររបស់ នួន ជា', ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០១៦។

វគ្គសវនាការនេះ[56]។

19. មេធាវីការពារក្ដីសូមស្នើដល់អង្គជំនុំជម្រះឱ្យពន្លឿនសក្ខីកម្មរបស់បុគ្គលបីរូប ដែលធ្វើការនៅមន្ទីរ ២១ នៅក្នុងពេលដែលចោទប្រកាន់។ ដោយពិចារណាដល់ការទាក់ទងផ្ទាល់រវាងសាក្សីទាំងបី និង សាក្សីដែលត្រូវបានជ្រើសរើសរួចហើយដោយអង្គជំនុំជម្រះសម្រាប់មន្ទីរសន្តិសុខស២១ មេធាវី ការពារក្ដីស្នើសុំឱ្យស្ដាប់សក្ខីកម្មរបស់គាត់នៅបន្ទាប់ពីសក្ខីកម្មរបស់ ឌុច និងនៅមុនពេលការ មកផ្ដល់សក្ខីកម្មរបស់សាក្សីទាក់ទងនឹង "ការបោសសម្អាតផ្ទៃក្នុង"។

## ក. សាក្សីដែលត្រូវបានស្នើសុំ

### *(i) អតីតបុគ្គលិកនៅមន្ទីរសន្តិសុខ ស-២១ ([redacted] 2-TCW-864 [redacted] 2-TCW-854)*

20. មេធាវីការពារក្ដីបន្តរក្សាសេចក្ដីសន្និដ្ឋានរបស់ខ្លួន ទាក់ទិននឹងសាក្សីទាំងពីរនាក់នេះ[57] និងផ្ដល់ យោបល់ថា ការផ្ដោតទៅលើភ័ស្ដុតាងរបស់ពួកគេស្ដីពីមន្ទីរសន្តិសុខ ស-២១ ជាការសមហេតុផល បំផុតដែលត្រូវស្ដាប់សក្ខីកម្មសាក្សីទាំងនេះ នៅក្នុងវគ្គមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ដែលកំពុងដំណើរការជំនុំជម្រះ។ ការស្ដាប់សក្ខីកម្មរបស់បុគ្គលទាំងពីរនេះនៅក្នុងអំឡុងពេលវគ្គ សវនាការនេះ វានឹងមិនគ្រាន់តែសមហេតុផល ដោយសារតែស២១ គឺកម្មវត្ថុនៃភស្ដុតាងរបស់គាត់ ប៉ុន្តែវានឹងថែមទាំងជួយផងដែរក្នុងការបង្ហាញការពិត។

21. ក្រៅពីនេះ មេធាវីការពារក្ដីលើកឡើងថា ភ័ស្ដុតាងរបស់ [redacted] (2-TCW-864) មានសារៈ សំខាន់ច្រើនយ៉ាង។ ទីមួយ គាត់ធ្លាប់ធ្វើការនៅក្នុងក្រុមសួរចម្លើយនៅមន្ទីរសន្តិសុខ ស-២១ និងជា [redacted] ជាបញ្ហាសំខាន់ជាខ្លាំងនាពេល នេះ ដោយសារថា [redacted] នៅមន្ទីរសន្តិសុខ ស-២១ គឺប្រធានបទសំខាន់មួយក្នុងចំណោមប្រធានបទសំខាន់ៗនៃសវនាការស្ដីពី មន្ទីរសន្តិសុខ ស-២១ ក្នុងសំណុំរឿង ០០២/០២។ សក្ខីកម្មរបស់ [redacted] (2-TCW-864) អាចផ្ដល់ជូន

---

[56] សូមមើលផងដែរការឆ្លើយតបនឹងដាក់ជូនចំពោះ E395/1 "សំណើសុំសារណាសង្ខេបស្ដីអំពីសារៈសំខាន់នៃក្រុមជម្លោះនៅក្នុង ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ" ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦។

[57] ឯកសារ E305/4.2 សេចក្ដីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ២៤-២៨ លេខ ១៨ និង ២១។

អង្គជំនុំជម្រះនូវព័ត៌មានស៊ីជម្រៅ ពិសេសទាក់ទិននឹងចំណុចនេះ[58]។ [redacted]។ ហេតុនេះ ការស្តាប់សក្ខីកម្មរបស់គាត់ដោយផ្ទាល់ទៅលើឯកសារជាក់លាក់នោះ ដែលនាពេលនេះមានសារៈសំខាន់ជាខ្លាំង ដោយសារគាត់នឹងអាចបំភ្លឺ*ក្នុងចំណោមនោះ*ទៅលើសុក្រឹត្យភាព និងដំណើរការគ្រប់គ្រងឯកសារ និង ទៅលើការបណ្តុះបណ្តាលដែលពួកសន្តិសុខ និងអ្នកសួរចម្លើយនៅមន្ទីរសន្តិសុខ ស-២១ បានទទួល។ ចុងក្រោយ បើតាមភស្តុតាងជាលាយលក្ខណ៍អក្សរ [redacted] (2-TCW-864) នឹងអាចផ្តល់ភស្តុតាងដោះបន្ទុកសំខាន់ ដែលទាក់ទងនឹងការដោះលែងអ្នកទោស[61] និងដំណើរការជ្រើសរើសមនុស្សដើម្បីបញ្ជូនទៅព្រៃស[62] ជាបញ្ហានានាដែលបានពិភាក្សាយ៉ាងច្រើននៅក្នុងវគ្គស២១។ ចុងក្រោយ បើតាម ឌុច [redacted] (2-TCW-864) ជាអ្នកដែលបានសួរចម្លើយ និងរៀបចំប្រតិចារឹកមួយផ្នែកចំពោះចម្លើយសារភាពរបស់ [redacted] (2-TCW-956) ជាសាក្សីម្នាក់ទៀត ដែលមេធាវីការពារក្តីស្នើសុំឲ្យពន្លឿនការកោះហៅមកផ្តល់សក្ខីកម្ម[63]។

22. [redacted] (2-TCW-854) គឺជា [redacted] និងជាអ្នកថតរូបមុនគេដែលបានទៅដល់មន្ទីរសន្តិសុខ ស-២១[64]។ បើតាមកំណត់ហេតុនៃការស្តាប់ចម្លើយរបស់គាត់ គាត់អាចផ្តល់ភស្តុតាងយ៉ាងទូលំទូលាយទៅលើប្រធានបទនានាដែលទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ ដែលសាក្សីផ្សេងៗទៀតមិនអាចផ្តល់ភស្តុតាងលម្អិតដូចនេះបាន។ ជាពិសេស [redacted] (2-TCW-854) នឹងអាចផ្តល់ព័ត៌មានពិសេស ទាក់ទិននឹងអង្គហេតុថា បុគ្គលមួយចំនួន

---

58 [redacted] "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] [2-TCW-864]" ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ ("កំណត់ហេតុស្តាប់ចម្លើយ [redacted] (2-TCW-864)") [redacted]។

59 [redacted]។

60 [redacted]។

61 [redacted] កំណត់ហេតុស្តាប់ចម្លើយ [redacted] (2-TCW-864) លេខ EN 00164387។

62 [redacted] កំណត់ហេតុស្តាប់ចម្លើយ [redacted] (2-TCW-864) លេខ EN 00164388។

63 *សូមមើល ខាងក្រោម* នៅត្រង់កថាខណ្ឌ ២០។

64 [redacted] "កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] (2-TCW-854)" ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៧ ("កំណត់ហេតុស្តាប់ចម្លើយ [redacted] ឆ្នាំ ២០០៧ (2-TCW-854)") [redacted]។

ដែលត្រូវបានចុះឈ្មោះ និងថតរូបនៅមន្ទីរសន្តិសុខ ស-២១ បន្ទាប់មកត្រូវបានបញ្ជូនទៅព្រៃស[65]។ ធាតុផ្សំនេះគឺជាគន្លឹះចំពោះការចោទប្រកាន់ថា អ្នកទោសទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ហើយចុងក្រោយត្រូវបានគេសម្លាប់។ ក្រៅពីនេះ ភ័ស្តុតាងរបស់ [redacted] (2-TCW-854) ជាប់ពាក់ព័ន្ធទៅនឹងដំណើរការទូទៅនៃការថតរូបនៅមន្ទីរសន្តិសុខ ស-២១ និងការប្រើប្រាស់រូបថតក្រោយពេលថតរួច រួមទាំងការភ្ជាប់ថតរូបទាំងនោះទៅនឹងប្រវត្តិរូប និងជាមួយបញ្ជីដែលមានការអះអាងថា សួស ធី (2-TCW-816) ជាអ្នករៀបចំ[66]។

23. នៅក្នុងសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់គាត់ [redacted] (2-TCW-854) ក៏ផ្តល់ភ័ស្តុតាងដែលផ្ទុយ និងអាចស្រប ឬជំទាស់ទៅនឹងសច្ចៈសីលភាពនៃព័ត៌មានដែលសាក្សី ញ៉ែម អេន បានផ្តល់ ទៅលើប្រធានបទមួយចំនួន ជាពិសេសរួមមាន៖

(ក) ការមកដល់ និងតួនាទីរបស់ ញ៉ែម អេន នៅមន្ទីរសន្តិសុខ ស-២១ និងការអះអាងរបស់ ញ៉ែម អេន ដែលថា [redacted]។

(ខ) អង្គហេតុដែលថា រូបថតត្រូវបានថតពីអ្នកទោសម្នាក់ៗ[68]។

(គ) ចំនួនអ្នកទោសសរុបដែលត្រូវបានថតរូប តាមការប៉ាន់ស្មានប្រហែល ២.000-៣.000

---

[65] [redacted]។

[66] ឯកសារ [redacted] កំណត់ហេតុស្តាប់ចម្លើយ [redacted] ឆ្នាំ ២00៧ (2-TCW-854) [redacted]។

[67] ឯកសារ [redacted] កំណត់ហេតុស្តាប់ចម្លើយ [redacted] (2-TCW-854) ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២00៨ [redacted]។

[68] ឯកសារ [redacted] កំណត់ហេតុស្តាប់ចម្លើយ [redacted] ឆ្នាំ ២00៧ (2-TCW-854) [redacted]។

នាក់[69]។

(ឃ) ការចាប់ខ្លួនកម្មាភិបាលនៅមន្ទីរសន្តិសុខ ស-២១ ដោយលើកឡើងថា ៣-៤ នាក់ត្រូវបានចាប់ខ្លួន រួមទាំងអ្នកដែលត្រូវបានចោទប្រកាន់ថាបានរំលោភសេពសន្ថវៈអ្នកទោសម្នាក់[70]។

(ង) វត្តមានរបស់កុមារ ដែលគាត់បានលើកឡើងថា គាត់ពុំឃើញមានកុមារណាម្នាក់ទេ[71]។ និង

(ច) ប្រព័ន្ធនៃការកត់ត្រាចំនួនអ្នកទោសដែលបានថតរូប និង ការអះអាងរបស់ ញ៉ែម អេន ដែលថា កូនក្រុមគាត់ជាអ្នកធ្វើ ហើយថា វាមិនមែនជាប្រព័ន្ធនៃការកត់ត្រាលេខតាមលំដាប់លំដោយទេ តែរបៀបព្រាវៗ[72]។

24. ចុងក្រោយ ប៉ុន្តែសំខាន់ យោងតាម ញ៉ែម អេន[73] [redacted] (2-TCW-854) [redacted] (2-TCW-854) នឹងអាចបញ្ជាក់អំពីការអះអាងរបស់ ញ៉ែម អេន និងផ្តល់នូវការបញ្ជាក់បំភ្លឺបន្ថែមទៀត ពាក់ព័ន្ធប្រភពដើមនៃឯកសារ និងភាពត្រឹមត្រូវនៃឯកសារទាំងនេះ និងជាពិសេស ដំណើរការក្នុងការដាក់លេខ។

***(ii) អតីតអ្នកជាប់ឃុំម្នាក់នៅមន្ទីរ ស-២១ ([redacted] –2-TCW-956)***

---

[69] ឯកសារ [redacted] កំណត់ហេតុស្តាប់ចម្លើយ [redacted] ឆ្នាំ ២០០៧ (2-TCW-854) [redacted]។

[70] ឯកសារ [redacted] កំណត់ហេតុស្តាប់ចម្លើយ [redacted] ឆ្នាំ ២០០៧ (2-TCW-854) [redacted]។

[71] ឯកសារ [redacted] កំណត់ហេតុស្តាប់ចម្លើយ [redacted] ឆ្នាំ ២០០៧ (2-TCW-854) [redacted]។

[72] ឯកសារ [redacted] កំណត់ហេតុស្តាប់ចម្លើយ [redacted] ឆ្នាំ ២០០៧ (2-TCW-854) [redacted]។

[73] [redacted]។

[74] ឯកសារ E394 "សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមរូបថត ស-២១ ទៅក្នុងបញ្ជីពាក់ព័ន្ធ ដែលបានទទួលយកជាឯកសារ E3/9214" ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦។

25. មេធាវីការពារក្តីរក្សាអំណះអំណាងរបស់ខ្លួន ទាក់ទិននឹងសាក្សីរូបនេះ និងស្នើឡើងថា ដោយសារតែភ័ស្តុតាងរបស់គាត់ផ្តោតទៅលើ ស-២១ ការស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះនៅក្នុងវគ្គសវនាការដែលកំពុងដំណើរការស្តីពីមន្ទីរសន្តិសុខ និង "ការបោសសំអាតផ្ទៃក្នុង" គឺជាការសមស្របបំផុត[75]។ លើសពីនេះទៀត មេធាវីការពារក្តីអះអាងថា [redacted] (2-TCW-956) អាចផ្តល់ភ័ស្តុតាងដែលគួរឲ្យចាប់អារម្មណ៍ *ក្នុងចំណោមប្រការផ្សេងទៀត* ទាក់ទិននឹងការអនុវត្តការសួរចម្លើយនៅ ស-២១ និងការផ្ទេរអ្នកទោសពី ស-២១ ទៅកាន់ព្រៃស។

26. [redacted] (2-TCW-956) បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០១ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់។ ទោះបីជាយ៉ាងណាក៏ដោយ ចុងក្រោយ អង្គជំនុំជម្រះបានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ដោយសន្និដ្ឋានថា៖

[redacted]។

27. មេធាវីការពារក្តីអះអាងថា សក្ខីកម្មរបស់ [redacted] (2-TCW-956) នៅក្នុងសំណុំរឿង ០០១ ត្រូវបានរំខានជាច្រើនលើក ដូចជា [redacted]

---

[75] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ២៣ លេខ ១៧។

[76] ឯកសារ E188 "សាលក្រម សំណុំរឿង ០០១" ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ទំព័រ ៣៧៥។

[77] ឯកសារ [redacted] ប្រតិចារឹក សំណុំរឿង ០០១ [redacted] (2-TCW-956 [redacted]

[redacted]។

28. ផ្ទុយទៅវិញ មេធាវីការពារក្ដីអះអាងថា សក្ខីកម្មរបស់បុគ្គលរូបនេះមានភាពពាក់ព័ន្ធ និងគួរឱ្យជឿជាក់បាន។ តាមពិត វាទំនងជាថា ការចុះបញ្ជីដែលបញ្ជាក់អំពីអ្នកទោសម្នាក់ឈ្មោះ [redacted] ដែលអះអាងថាត្រូវបានសម្លាប់នៅថ្ងៃទី "??-??-៧៥?" យោងតាមបញ្ជីឈ្មោះអ្នកទោសរបស់ ក.ស.ព នេះ[81] អាចជាកំហុសឆ្គង ដោយសារតែ "បញ្ជីឈ្មោះថ្មីរបស់ ក.ស.ច.ស" មិនបានបញ្ជាក់អំពីកាលបរិច្ឆេទនៃការសម្លាប់បុគ្គលរូបនេះឡើយ[82]។ បន្ថែម លើនេះទៀត ផ្ទុយទៅនឹងការអះអាងរបស់អង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០១ ដែលថាពុំមានភស្តុតាងគាំទ្រដល់អត្ថិភាពនៃការដោះលែង និងបញ្ជូនអ្នកជាប់ឃុំពីមន្ទីរ ស-២១ ទៅព្រៃសនោះ ដែលភស្តុតាងទាំងនេះគឺមាននៅក្នុងសំណុំរឿងបច្ចុប្បន្ននេះ[83]។ លើសពីនេះទៀត ឌុច បានអះអាងថា ចម្លើយសារភាពរបស់ [redacted] ត្រូវបានកត់ត្រាមួយផ្នែកដោយ [redacted] (2-TCW-864)[84] ដែល អាចបញ្ជាក់អំពីភាពត្រឹម

---

[78] ឯកសារ [redacted] ប្រតិចារឹក សំណុំរឿង ០០១ [redacted] (2-TCW-956) ចាប់ពី [redacted]។

[79] ឯកសារ E3/1662 "បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ព" ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩។

[80] ឯកសារ E3/7454 ប្រតិចារឹក សំណុំរឿង ០០១ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៩ (លី ហ៊ី) (2-TCW-956), [15.16.49] "ហើយផងដែរនៅក្នុងបញ្ជីកម្មេចរបស់ មន្ទីរ ស-២១ ដែលសហព្រះរាជអាជ្ញាបានរៀបចំជូនហ្នឹង មានប្រហែល ៣០០ ទំព័រ ហើយឈ្មោះរបស់បុគ្គលរូបនេះ នៅត្រង់ទំព័រ ៥៩ -- លោក/លោកស្រីអាចរកមើលឈ្មោះរបស់ អ៊ា ហ៊ី នេះនៅត្រង់លេខរៀង ១៩៧២។ ប្រសិនបើលោក/លោកស្រី មើលលេខរៀងនេះ លោក/លោកស្រីអាចដឹងថា អ៊ា ហ៊ី ស្លាប់បាត់ហើយ"។

[81] ឯកសារ E3/1662 "បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ព" ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ [redacted]។

[82] ឯកសារ E393.2 "បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស" ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ [redacted]។

[83] សូមមើល ឯកសារ E3/5159 "កំណត់ហេតុនៃការស្ដាប់ចម្លើយ ញ៉ែម នី ហៅ ភា" ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៣, ឯកសារ E3/7664 "កំណត់ហេតុនៃការស្ដាប់ចម្លើយ សុខ សុផាត" ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៨, ឯកសារ E3/7543 "កំណត់ហេតុនៃការស្ដាប់ចម្លើយ គុប រី" ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៣។

[84] ឯកសារ [redacted] ប្រតិចារឹក សំណុំរឿង ០០១ ថ្ងៃទី [redacted]។

ត្រូវនៃសក្ខីកម្មរបស់ [redacted] (2-TCW-956) ប្រសិនបើអង្គជំនុំជម្រះ យល់ស្របតាមសំណើរបស់មេធាវីការពារក្ដី និងកោះហៅគាត់ឲ្យមកផ្ដល់សក្ខីកម្មនោះ។

**ខ. សាក្សីដែលអាចផ្ដល់សក្ខីកម្ម ពាក់ព័ន្ធនឹងប្រភពឯកសារ ដំណើរការនៃការរក្សាឯកសារ និងយថាភាពនៃឯកសារ ទាក់ទិននឹងមន្ទីរសន្តិសុខ ស-២១**

***(i) សាក្សីចំនួនបីរូបដែលមេធាវីការពារក្ដីបានស្នើសុំក្នុងពេលកន្លងមក ([redacted] 2-TCW-870, [redacted] 2-TCW-81 និង [redacted] 2-TCW-963)***

29. [redacted]។ មេធាវីការពារក្ដីរក្សាសេចក្ដីសន្និដ្ឋានរបស់ខ្លួន ទាក់ទិននឹងសាក្សីទាំងបីរូបនេះ[86] ដែលបច្ចុប្បន្ននេះគឺជាបុគ្គលដែលដឹងច្រើនជាងគេបំផុត ទាក់ទិននឹងឯកសារមន្ទីរ ស-២១។ ពួកគាត់នឹងអាចផ្ដល់នូវភ័ស្ដុតាងដ៏មានសារៈសំខាន់ និងមានលក្ខណៈពិសេស អំពីដំណើរការនៃការរក្សាឯកសារទាំងនេះ និងផ្ដល់នូវការយល់ដឹងលម្អិត ពាក់ព័ន្ធនឹងយថាភាពនៃឯកសារគន្លឹះមួយចំនួន ដែលអង្គជំនុំជម្រះ និងភាគីនានាយកមកធ្វើជាសំអាងនៅក្នុងអំឡុងវគ្គសវនាការដែលកំពុងដំណើរការនេះ។

30. លើសពីនេះទៀត មេធាវីការពារក្ដីអះអាងថា សាក្សីទាំងបីរូបនេះ ដែលបានធ្វើការលើឯកសារមន្ទីរ ស-២១ តាំងពីបង្កើតសារមន្ទីរទួលស្លែងនេះមក នឹងអាចផ្ដល់នូវភ័ស្ដុតាងដ៏មានសារៈសំខាន់ អំពីសមាសភាពនៃឯកសារដើមដែលបានរកឃើញនៅក្នុងឆ្នាំ ១៩៧៩ និងការជ្រើសរើស និងការប្រើប្រាស់ឯកសារទាំងនេះពីសំណាក់ដៃគូពាក់ព័ន្ធផ្សេងៗ។ [redacted]

---

[85] ឯកសារ [redacted] "កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [redacted] (2-TCW-963)" [redacted]។

[86] ឯកសារ E305/4.2 សេចក្ដីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ៣ លេខ ៥។

[redacted]។ សក្ខីកម្មរបស់សាក្សីទាំងបីរូបនេះនឹង អាចឱ្យអង្គជំនុំជម្រះ និងភាគីនានាធ្វើប៉ាន់ស្មានអំពីវិសាលភាពដែលសំណុំរឿងនេះមានវិការៈ និងមានលក្ខណៈមិនពេញលេញ និងដើម្បីវាយតម្លៃអំពីភាពគួរឱ្យជឿជាក់បាននៃសំណុំភ័ស្តុតាងដែលអង្គជំនុំជម្រះ និងភាគីនានាអាចរកមើលបាននៅពេលបច្ចុប្បន្ននេះ។ ជាលទ្ធផល មេធាវីការពារក្តីស្នើសុំឱ្យកោះហៅគាត់សម្រាប់វគ្គសវនាការស២១។

*(ii)* ***អ្នកនិពន្ធ [redacted] ឆ្នាំ ១៩៨១ អំពីស២១ ([redacted] 2-TCW-946)***

31. [redacted] (2-TCW-946) គឺជាអ្នកថតខ្សែភាពយន្តម្នាក់ដែលបានផលិតភាពយន្តឯកសារ ចំនួនពីរ ពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ[88]។ ភាពយន្តឯកសារមួយក្នុងចំណោមភាពយន្តឯកសារទាំងពីរនោះ ដែលមានចំណងជើងថា [redacted] មានលក្ខណៈពិសេសណាស់ ដោយសារតែភាពយន្តនេះ ភាគច្រើនត្រូវបានថតឡើងនៅក្នុងបរិវេណមន្ទីរ ស-២១ [redacted]។ ជាពិសេស ភាពយន្តនេះបង្ហាញលម្អិតអំពីផ្នែកនៃឯកសារដើម ដែលបានរកឃើញនៅមន្ទីរស-២១ [redacted]។ តាមដែលមេធាវីការពារក្តីដឹង ឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងនេះ ដែលជាភ័ស្តុតាងដើមសម្រាប់វគ្គសវនាការដែលកំពុងបន្តដំណើរការ ដូចជា ឧទាហរណ៍ កូនសៀវភៅពណ៌ទឹកក្រូចដែលចងក្រងកំណត់ហេតុប្រចាំថ្ងៃរបស់អ្នកទោស[90] លែងឃើញមានទៀតហើយចាប់តាំងពីពេលនោះមក និងលើសពីនេះទៀត មិនដែលឃើញយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះឡើយ។ [redacted] (2-TCW-946) បានឱ្យដឹងថា ផ្នែកនៃឯកសារដើមនេះ បាត់លែងឃើញ

---

87 [redacted]។

88 [redacted]។

89 [redacted]

90 [redacted]

មានទៀតហើយ និងជាពិសេស រូបថតមួយចំនួនដែលត្រូវបានប្រទះឃើញនៅក្នុងឆ្នាំ ១៩៧៩ និង ១៩៨០[91]។ អាស្រ័យហេតុនេះហើយ គឺជាបុគ្គលតែម្នាក់គត់អាចផ្តល់ភស្តុតាងទៅលើឯកសារទាំងនេះ។

32. មេធាវីការពារក្តីអះអាងថា សក្ខីកម្មរបស់ [redacted] (2-TCW-946) មានសារៈសំខាន់ណាស់ ពាក់ព័ន្ធនឹងវគ្គសវនាការដែលកំពុងដំណើរការនេះ ដោយសារតែភាពយន្តរបស់គាត់ផ្តល់នូវការយល់ដឹងច្បាស់លាស់ ទាក់ទិនទៅនឹងឯកសារដែលបានរកឃើញនៅមន្ទីរ ស-២១។ លើសពីនេះទៀត នៅពេលដាក់បញ្ជីឈ្មោះសាក្សីដំបូងរបស់ខ្លួនសម្រាប់សំណុំរឿង ០០២ មេធាវីការពារក្តីបានជូនដំណឹងអង្គជំនុំជម្រះថា សាក្សីរូបនេះមានវ័យចំណាស់ហើយ និងបានស្នើឲ្យអង្គជំនុំជម្រះពន្លឿនការស្តាប់សក្ខីកម្មរបស់គាត់ និងអាចធ្វើឡើងតាមរយៈបណ្តាញសោតទស្សន៍[92]។ បច្ចុប្បន្ននេះ [redacted] (2-TCW-946) [redacted] ហើយមេធាវីការពារក្តីអះអាងថា គួរតែមានការស្តាប់សក្ខីកម្មរបស់គាត់ឲ្យបានឆាប់រហ័សបំផុត។

***(iii) អ្នកបង្កើតបញ្ជីសាក្សី កសចស ([redacted] សាក្សី ១ និង [redacted] សាក្សី ២)***

33. នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានទទួលយកបញ្ជីឈ្មោះរបស់ ក.ស.ច.ស[93]។ បញ្ជីឈ្មោះនេះបង្ហាញឈ្មោះបុគ្គលចំនួន ១៥ ១០១ នាក់ ដែលត្រូវបានចោទប្រកាន់ថាបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១[94]។ ដោយសារតែពេលវេលាមានកម្រិត មេធាវីការពារក្តីបានធ្វើការវិភាគសើៗទៅលើឯកសារនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ការពិនិត្យមើលយ៉ាងលឿននេះ បានបង្កើតនូវចម្ងល់យ៉ាងខ្លាំងរួចទៅហើយអំពីវិធីសាស្ត្រដែលបានយកមកប្រើដើម្បីចងក្រងបញ្ជីឈ្មោះនេះ – ជាពិសេស ទាក់ទិននឹងការប្រើប្រាស់ឯកសារ និងការរៀបចំទិន្នន័យ។ ឧទាហរណ៍ មេធាវីការពារក្តីបានកំណត់បុគ្គលចំនួន ៤០៦ នាក់នៅក្នុងបញ្ជី ដែលពុំមានកាលបរិច្ឆេទចូល កាល

---

[91] ឯកសារ E3/1684 សៀវភៅនិពន្ធដោយលោក Chandler សំឡេងពីមន្ទីរ ស-២១ ឆ្នាំ ១៩៩៩ វគ្គទី ១ កំណត់សម្គាល់ចុងទំព័រ ៧ ERN 00192019។

[92] ឯកសារ E305/4.2 សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពលើសាក្សី ទំព័រ ១៤ លេខរៀងទី ១០។

[93] ឯកសារ E393 "អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សេចក្តីសម្រេចស្តីពីការទទួលយកបញ្ជីថ្មីនៃឈ្មោះអ្នកជាប់ឃុំដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្កើតឡើង" ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦។

[94] ឯកសារ E393.2 "បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស" ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦។

បរិច្ឆេទចាប់ខ្លួន និងសម្លាប់ឡើយ[95]។ ដូច្នេះ មេធាវីការពារក្តីមិនមានតួនាទីក្នុងពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានដែលអ្នកស៊ើបអង្កេតបានផ្អែកទៅលើ ដើម្បីកំណត់អត្តសញ្ញាណបុគ្គលទាំង ៤០៦ នាក់នោះជាអ្នកទោសមន្ទីរ ស-២១ នោះឡើយ។ ដូចគ្នានេះដែរ មេធាវីការពារក្តីបានកត់សម្គាល់ថា ក្នុងចំណោមឯកសារចំនួន ៨៧១ ឯកសារ បានយកមកប្រើនោះ មានតែ ៣២ ឯកសារ ប៉ុណ្ណោះជាឯកសារដើម។ ឯកសារផ្សេងៗទៀត យ៉ាងច្រើនដែលអ្នកស៊ើបអង្កេតបានយកមកប្រើដើម្បីបង្កើតបញ្ជីឈ្មោះនេះ គឺជាឯកសារថតចម្លង ឬឯកសារស្កេន។ លើសពីនេះទៀត ឯកសារមួយចំនួនដែលបានយកមកប្រើនោះ មានទម្រង់ខុសប្រក្រតី, ឯកសារមួយចំនួនមាននិមិត្តសញ្ញាតំណាងឲ្យនគរបាលជាតិពីរបបមុន[96], ឯកសារមួយចំនួនផ្សេងទៀត មានចំណារជាភាសាផ្សេងៗ ដូចជាភាសាវៀតណាម ឬបារាំង[97] ហើយចុងក្រោយ ប៉ុន្តែក៏សំខាន់ដែរ ឯកសារមួយចំនួនគឺអានអត់ដាច់ ដោយសារតែអក្សរទាំងនោះស្ទើរតែរលប់អស់ហើយ[98]។

34. មេធាវីការពារក្តីបានជូនដំណឹងរួចហើយដល់អង្គជំនុំជម្រះអំពីបញ្ហាធ្ងន់ធ្ងរផ្នែកវិធីសាស្ត្រមួយចំនួន នៅក្នុងសំណើបន្ទាន់របស់ខ្លួនសុំពេលវេលាបន្ថែមដើម្បីរៀបចំសម្រាប់ពិនិត្យសាក្សី ស-២១ ដែលនៅសេសសល់ ដើម្បីការពារដល់សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការកាត់សេចក្តី ដោយយុត្តិធម៌[99]។ នៅពេលនេះ មេធាវីការពារក្តីមានមន្ទិលកាន់តែខ្លាំងថែមទៀត អំពីប្រភពដើមកាលបរិច្ឆេទ និងភាពត្រឹមត្រូវទូទៅនៃឯកសារចំនួន ៨៧១ ឯកសារ ដែលអ្នកស៊ើបអង្កេតបានយកមកប្រើ។ ដូច្នេះ មេធាវីការពារក្តីអះអាងថា វាមានសារៈសំខាន់ណាស់ក្នុងការស្តាប់សក្ខីកម្មបុគ្គលទាំងពីររូបនោះ [redacted] គឺ [redacted] (សាក្សីទី១) [redacted]

---

[95] ឯកសារ E393.2 "បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស" ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ លេខចូល 14099, 14160, 14238, 14374, 14502, 14583, 14677, 14689, 14690 and 14938។

[96] E3/10399 "បញ្ជីឈ្មោះអ្នកទោសមកពីកងពល១៦៤"។ E3/10400"បញ្ជីឈ្មោះអ្នកទោសមកពីកងពល១៧០"។

[97] សូមមើល ឯកសារ E3/10381 "បញ្ជីឈ្មោះអ្នកទោសចូលថ្ងៃទី ១៤/៤/៧៨", E3/1700 "បញ្ជីឈ្មោះអ្នកទោសមកពីមន្ទីរ និងក្រសួងនានាចូលថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៧", E3/3185 "បញ្ជីឈ្មោះអ្នកទោសស្លាប់ពីថ្ងៃទី ១៥-៣១/១/៧៧", E3/9845 "បញ្ជីឈ្មោះអ្នកទោសចូល ខែ មីនា ឆ្នាំ ១៩៧៧។

[98] សូមមើល ឯកសារ E3/10103, E3/10457, E3/10495។

[99] ឯកសារ E402 "សំណើបន្ទាន់របស់ នួន ជា សុំពេលវេលាបន្ថែមដើម្បីរៀបចំសម្រាប់ការពិនិត្យសាក្សី ស២១ ដែលនៅសេសសល់ ដើម្បីការពារដល់សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌" ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦។

និងលោក [redacted] (សាក្សីទី២) [redacted]។ សាក្សីទាំងនេះនឹងអាចផ្តល់នូវការពន្យល់លម្អិតអំពី *ក្នុងចំណោមការពន្យល់ ផ្សេងទៀត* វិធីសាស្ត្រដែលបានអនុវត្ត, លក្ខណៈនៃឯកសារដើមដែលពួកគាត់បានយកមកធ្វើជាសំអាង និងការជ្រើសរើសឯកសារនេះ។ មេធាវីការពារក្តីសូមគូសបញ្ជាក់ថា ការបញ្ជាក់បំភ្លឺពី [redacted] គឺកាន់តែមានសារៈសំខាន់ថែមទៀត ដោយសារតែបញ្ជីឈ្មោះរបស់ ក.ស.ច.ស បានគឺជាឯកសារគន្លឹះមួយសម្រាប់ភាគីយោងទៅនៅក្នុងពេលវគ្គសវនាការដែលកំពុងដំណើរការនេះ យថាភាព និងភាពអាចជឿជាក់បានដែលវាសំខាន់សម្រាប់បញ្ជាក់ការពិត។

*(iv)* [redacted] *សាក្សី៣)*

35. នៅក្នុងបញ្ជីឯកសាររបស់ខ្លួនដែលបានដាក់នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យទទួលយកលិបិក្រមមួយនៃការប្រមូលផ្តុំរូបថត ស-២១ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានឯកសារនេះត្រូវបានអង្គជំនុំជម្រះទទួលយកជាឯកសារ [redacted][101]។ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានដាក់សំណើមួយសុំបន្ថែមរូបថត ស-២១ ទៅក្នុងបញ្ជីពាក់ព័ន្ធ ដែលបានទទួលយកជា [redacted][102]។ យោងតាមព័ត៌មាននៅខាងលើបញ្ជីនេះ បុគ្គលដែលមានឈ្មោះ [redacted] (សាក្សីទី៣) បានផ្តល់រូបថតទាំងនោះទៅឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១២[103]។ ពុំ [redacted]។ ដូច្នេះ មេធាវីការពារក្តីអះអាងថា [redacted] (សាក្សីទី៣) គួរត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម ដើម្បីបញ្ជាក់បំភ្លឺអំពីយថាភាព និងដំណើរការនៃការរក្សា

---

[100] ឯកសារ E393.1 "អនុស្សរណៈអន្តរការិយាល័យ - បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស និងការពន្យល់អំពីវិធីសាស្ត្រដែលបានអនុវត្ត" ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦។

[101] ឯកសារ E305/13.23 បញ្ជីឯកសារដែលបានធ្វើបច្ចុប្បន្នភាពរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០(៣)(ឃ) ឧបសម្ព័ន្ធ គ២ - ឯកសារមិនមាននៅក្នុងសំណុំរឿង ០០២ លេខ ៦៦ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។

[102] [redacted]។

[103] [redacted]។

ទុករូបថតទាំងនោះ ដែលធាតុផ្សំទាំងពីរនេះមានសារៈសំខាន់នៅពេលកំណត់អំពីតម្លៃរបស់ភស្តុតាង។

### (v) *មេធាវីការពារក្តីមិនបានរំពឹងទុកអំពីការកោះហៅសាក្សីថ្មីបីរូប*

36. សក្ខីកម្មដែលរំពឹងទុករបស់សាក្សីទាំងពីររូបនេះ គឺ *ជាបឋម* គួរឲ្យជឿជាក់បាន និងមានភាពជាប់ពាក់ព័ន្ធ និងមានប្រយោជន៍យ៉ាងច្រើនក្នុងការបញ្ជាក់ការពិត។ ដូចដែលបានបញ្ជាក់ពីខាងលើ គឺជាផលប្រយោជន៍នៃយុត្តិធម៌ក្នុងការស្តាប់សក្ខីកម្មរបស់ [redacted] (សាក្សីទី១) និងលោក [redacted] (សាក្សីទី២) សម្រាប់ប្រធានបទមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ដោយសារតែភាគីអាចនឹងពឹងផ្អែកយ៉ាងច្រើនទៅបញ្ជីឈ្មោះរបស់ ក.ស.ច.ស សម្រាប់ការរៀបចំ និងការសួរទៅកាន់សាក្សីដែលនឹងមកផ្តល់សក្ខីកម្មទាក់ទងនឹង វគ្គសវនាការដែលកំពុងដំណើរការនេះ ។ ដោយសារតែបញ្ជីឈ្មោះអ្នកទោសរបស់ ក.ស.ច.ស បានដាក់បង្ហាញរួចហើយទៅដល់ភាគីនានា នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៦ ទើប មេធាវីការពារក្តីអះអាងបន្ថែមទៀតថា សំណើនេះមិនមែនជាសំណើដែលបានដាក់យឺតពេលនោះឡើយ ដោយសារថា មេធាវីការពារក្តីមិនអាចរំពឹងទុកក្នុងការស្នើសុំកោះហៅបុគ្គលនេះ។ ហើយសំណើនេះគឺអនុវត្តដូចគ្នាទាក់ទិននឹង [redacted] (សាក្សី ៣)។

## V. សំណូមពរ

37. យោងតាមហេតុផលដែលបានបញ្ជាក់ជូនខាងលើ មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះ៖

(i) កោះហៅ [redacted] (2-TCW-864), [redacted] (2-TCW-854), [redacted] (2-TCW-956) [redacted] ( 2-TCW-946), [redacted] (2-TCW-870) និង [redacted] (2-TCW-81) មកផ្តល់សក្ខីកម្មឲ្យបានឆាប់រហ័ស នៅក្នុងអំឡុងវគ្គសវនាការស្តីអំពីមន្ទីរសន្តិសុខ និង "ការបោសសំអាតផ្ទៃក្នុង" និង

(ii) អ្នកស្រី [redacted] (សាក្សីទី១) និងលោក [redacted] (សាក្សីទី២) កោះហៅ និង [redacted] (សាក្សី ៣) ឲ្យមកផ្តល់សក្ខីកម្មដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅក្នុងអំឡុងពេលវគ្គសវនាការអំពីមន្ទីរសន្តិសុខ និង "ការបោស

សម្អាតផ្ទៃក្នុង"។

**សហមេធាវីការពារក្តីរបស់ នួន ជា**

**សុន អរុណ** **Victor Koppe**